អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ធម៌ដែលនាំឲ្យប្រទេសរឹងមាំ ។

www.hoksavann.org
ថ្ងៃទី២ វិច្ឆិកា ២០១១



ក្នុងគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា បានសំដែងអំពីធម៌៧យ៉ាង ដែលធ្វើឲ្យប្រទេសណាយកទៅអនុវត្ត នឹងធ្វើឲ្យប្រទេសនោះរឹងមាំ មានការលូតលាស់ចំរើន សេចក្តីវិនាសមិនមានឡើយ ហើយបរទេសមិនអាចចូលមកឈ្លានពានបាន ។ ធម៌នេះព្រះពុទ្ធសំដែងប្រារព្ធចំពោះព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការព្រាហ្មណ៍ ដោយមានសេចក្តីដំណាលថា ព្រះបាទអជាតសត្រូវសោយរាជ្យក្នុងដែនមគធៈ មានព្រះបំណងទៅវាយយកដែនវជ្ជី ។ ព្រះបាទអជាតសត្រូវជាពុទ្ធសាសនិកជន គោរពព្រះពុទ្ធយ៉ាងជ្រាលជ្រៅបំផុត ។ មុននឹងព្រះអង្គទៅធ្វើសឹកសង្គ្រាមច្បាំងយកដែនដីវជ្ជីរបស់ពួកក្សត្រវជ្ជី ព្រះអង្គបានប្រើព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការព្រាហ្មណ៍ ឲ្យទៅថ្វាយបង្គំព្រះពុទ្ធ ទូលព្រះពុទ្ធអំពីបំណងរបស់ព្រះអង្គ ។ ព្រះបាទអជាតសត្រូវបានចាត់អាមាត្យរបស់ព្រះអង្គឲ្យទៅទូលព្រះពុទ្ធនេះ ដោយមានព្រះបំណងថា បើច្បាំងឈ្នះឬមិនឈ្នះ ស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គនឹងបានដឹងការពិត ព្រោះព្រះពុទ្ធមិនដែលមានព្រះពុទ្ធដីកាខុសទេ ។ ពេលនោះ វស្សការព្រាហ្មណ៍ជាមហាមាត្យរបស់ព្រះបាទអជាតសត្រូវបានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលព្រះពុទ្ធតាមបណ្តាំរបស់ព្រះរាជាខ្លួន ។ ព្រះពុទ្ធបានជ្រាបពីបំណងនេះហើយ ទើបព្រះអង្គត្រាស់ទៅកាន់ព្រះអានន្ទដែលនៅក្បែរនោះថា ម្នាលអានន្ទ ធម៌៧យ៉ាងដែលតថាគតនឹងពន្យល់តទៅនេះ បើពួកក្សត្រដែនវជ្ជីនៅតែប្រព្រឹត្តតទៅទៀត បរទេសមិនអាចចូលឈ្លានពានបានឡើយ ។ ធម៌៧យ៉ាងនោះគឺ ៖ ១- ពួកក្សត្រដែនវជ្ជីឧស្សាហ៍ប្រជុំគ្នារឿយៗ ដើម្បីពិគ្រោះគ្នារកសេចក្តីចំរើន និងការកុំឲ្យមានសេចក្តីវិនាសរបស់ប្រទេសក្នុងបច្ចុប្បន្ននិងទៅអនាគត ។ ២- ព្រមព្រៀងគ្នាប្រជុំនិងព្រមព្រៀងគ្នាលើកការប្រជុំ ព្រមទាំងបំពេញការងារតាមមុខងារនាទីរបស់ខ្លួនឲ្យបានល្អត្រឹមត្រូវ ។ ៣- មិនបញ្ញត្តបន្ថែមនិងមិនដកច្បាប់ ដែលពួកក្សត្រមុនៗបានបញ្ញត្តមកហើយ ត្រូវធ្វើតាមច្បាប់ដែលមានមកនោះ ។ ៤- ត្រូវធ្វើសក្ការៈគោរពរាប់អាននិងជឿស្តាប់ពួកក្សត្រដែនវជ្ជីមានព្រះជន្មច្រើន ដែលមានការពិសោធន៍ក្នុងបញ្ហាស្រុកទេស ។ ៥- ពួកវជ្ជីក្សត្រមិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល និងពួកកុមារីក្នុងត្រកូលឲ្យទៅរួម ។ ពាក្យនេះទំនងជាមិនឲ្យរំលោភស្ត្រី ឬកុមារីក្នុងត្រកូលរបស់ខ្លួន ។ ៦- ធ្វើសក្ការៈគោរពរាប់អានបូជាចេតិយ ។ ពាក្យនេះតាមអដ្ឋកថាពោលថា ទីកន្លែងទេវតាដែលគេធ្លាប់គោរពបូជា ។ ៧- ម្នាលអានន្ទ ពួកក្សត្រក្នុងដែនវជ្ជីតែងមានបំណងថា ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខក្នុងដែនរបស់យើង ។

បន្ទាប់ពីព្រះអង្គមានពុទ្ធដីកាទៅកាន់ព្រះអានន្ទដូច្នេះហើយ ព្រះអង្គត្រាស់ទៅកាន់វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍អបរិហានិយធម៌ ដែលប្រែថា ធម៌មិនសាបសូន្យទាំង៧នេះ តាំងនៅក្នុងពួកវជ្ជីក្សត្រហើយ បើពួកវជ្ជីក្សត្រនៅតែប្រតិបត្តិធម៌នេះ អស់កាលត្រឹមណា សេចក្តីចំរើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ សេចក្តីសាបសូន្យមិនមានឡើយអស់កាលត្រឹមនោះ ។ វស្សការព្រាហ្មណ៍ក្រាបទូលព្រះពុទ្ធថា បពិត្រព្រះគោតមដ៏ចំរើន ពិតមែនហើយ កាលបើក្សត្រក្នុងដែនវជ្ជីរួបរួមគ្នាកាន់ធម៌ទាំង៧នេះ ព្រះបាទអជាតសត្រូវក្នុងដែនមគធៈ ជាព្រះរាជារបស់ខ្ញុំព្រះអង្គមិនអាចចាប់ពួកវជ្ជីក្សត្រដោយការច្បាំងបានទេ វៀរលែងតែការលួងលោមផ្លូវចិត្ត ឬរកមធ្យោបាយធ្វើឲ្យបែកបាក់សាមគ្គីគ្នា ធ្វើឲ្យខ្សោយកម្លាំង ទើបប្រទេសដទៃចូលទៅឈ្លានពានបាន ។

យោលទៅតាមព្រះពុទ្ធដីកាទៅកាន់វស្សការព្រាហ្មណ៍ ដែលចង់ដឹងឱវាទរបស់ព្រះអង្គ អំពីការទៅវាយយកប្រទេសក្នុងដែនវជ្ជី របស់ព្រះបាទអជាតសត្រូវនគរមគធៈបញ្ជាក់ថា ដែនវជ្ជីរបស់ក្សត្រវជ្ជី មានការសាមគ្គីគ្នារឹងមាំណាស់ សត្រូវមិនអាចចូលមកឈ្លានពានបានឡើយ ជាពិសេសពួកក្សត្រវជ្ជីកាន់ធម៌៧យ៉ាងដូចពោលមកហើយយ៉ាងខ្ជាប់ខ្ជួន ។ គោលសំខាន់ក្នុងការអនុវត្តន៍ គឺក្សត្រវជ្ជីបានប្រជុំគ្នាជាញឹកញាប់ជាអចិន្ត្រៃយ៍ ដើម្បីពិគ្រោះគ្នាអំពីបញ្ហាជាតិ យកយោបល់អំពីចាស់ទុំដែលធ្លាប់មានការពិសោធន៍ មិនបញ្ញត្តច្បាប់បន្ថែម មិនដកច្បាប់ដែលក្សត្រវជ្ជីមុនៗបានបញ្ញត្តហើយ ។ ផ្ទុយទៅវិញ បើក្សត្រវជ្ជីបែកសាមគ្គីគ្នា ដោយការញុះញង់ពីខាងក្រៅ ដែនវជ្ជីនឹងត្រូវវិនាស ដោយសត្រូវខាងក្រៅចូលមកលុកលុយ ។ ព្រះបាទអជាតសត្រូវមិនហ៊ានចូលទៅឈ្លានពានដែនវជ្ជីឡើយ ដោយឃើញកម្លាំងសាមគ្គីរបស់ក្សត្រវជ្ជី និងបានស្តាប់ព្រះឱវាទរបស់ព្រះពុទ្ធជាម្ចាស់ផង ។

ព្រះពុទ្ធដីការបស់ព្រះពុទ្ធទៅកាន់វស្សការព្រាហ្មណ៍នេះ ជាមេរៀនដ៏ល្អណាស់សំរាប់អ្នកដឹកនាំនិងពលរដ្ឋខ្មែរយកទៅសិក្សា ដើម្បីរៀបចំប្រទេសរបស់ខ្លួនឲ្យបានរឹងមាំ ។ ពាក្យរបស់ព្រះពុទ្ធនេះ ហាក់ដូចព្រះអង្គប្រាប់ព្រះបាទអជាតសត្រូវតាមរយៈវស្សការព្រាហ្មណ៍ថា កុំច្បាំងដណ្តើមយកដែនវជ្ជី ព្រះអង្គពុំបានជ័យជំនះឡើយ ព្រោះដែនវជ្ជីមានការសាមគ្គីគ្នា មិនបែកបាក់គ្នា ដោយប្រតិបត្តិតាមធម៌៧យ៉ាងដូចពោលខាងលើ តែធម្មតាព្រះពុទ្ធព្រះអង្គពុំពោលដោយចំដូច្នេះទេ ព្រះអង្គពោលជាធម៌ចំពោះព្រះអានន្ទ ឲ្យវស្សការព្រាហ្មណ៍ឮយកទៅប្រាប់ព្រះបាទអជាតសត្រូវ ។ ផ្ទុយទៅវិញ បើដែនវជ្ជីមិនប្រតិបត្តិតាមធម៌៧យ៉ាង បែកបាក់សាមគ្គីគ្នា ពុំមានឯកភាពជាតិ នឹងធ្វើឲ្យប្រទេសទទួលគ្រោះថ្នាក់ពីបរទេសឈ្លានពាន ជាពិសេសពេលនោះ គឺព្រះបាទអជាតសត្រូវដែលបំរុងលើកកងទ័ពច្បាំងយកប្រទេសនេះជាចំណុះ ពេលណាដែលដែនវជ្ជីនេះបែកបាក់គ្នា ។៚